# កិច្ចការបញ្ចប់មេរៀនទី៣ សិស្សឧស្សាហ៍

**អំណាន:** ចូរអានអត្ថបទខាងក្រោម រួចឆ្លើយនឹងសំណួរ ។

**សិស្សឧស្សាហ៍**

សុខា ជាសិស្សឧស្សាហ៍។

រាល់ព្រឹក នាងទៅរៀនទៀងទាត់ និងទាន់ពេលជានិច្ច ។ សុខាគោរពបទបញ្ជារបស់សាលារៀនបានត្រឹមត្រូវ។ ក្នុងថ្នាក់រៀន នាងយកចិត្តទុដាក់ ស្តាប់គ្រូពន្យល់ និងហ៊ានជម្រាបសួរគ្រូនៅពេលមិនយល់ ។ ពេលខ្លះនាងជួយពន្យល់មិត្តរួមថ្នាក់ ដែលរៀនយឺតទៀតផង ។ សុខាតែងណែនាំមិត្តភក្តិ កុំឱ្យដើរលេងផ្តេសផ្តាស ។ នៅផ្ទះ សុខាខំធ្វើលំហាត់ អានសៀវភៅ សិក្សាស្រាវជ្រាវ និងជួយធ្វើកិច្ចការផ្ទះ ។

ឪពុកម្តាយសុខា សប្បាយចិត្តណាស់ ព្រោះឃើញកូនខិតខំរៀនសូត្រ និងទទួលបានផទផលល្អជាទីគាប់ចិត្ត ។

គូសសញ្ញា ✓ ក្នុងប្រអប់ ☐ ចម្លើយមួយដែលត្រឹមត្រូវ ។

១. តើសុខាជាសិស្សដូចម្តេច ?

☐ ក. ដើរលេងច្រើន ☐ ខ. តមាត់ជាមួយគ្រូ

☐ គ. ឧស្សាហ៍រៀនសូត្រ ☐ ឃ. បង្កជម្លោះក្នុងថ្នាក់រៀន

២. តើនៅក្នុងថ្នាក់រៀនសុខា ធ្វើអ្វីខ្លះ ?

☐ ក. ឡូឡា និងរំខានមិត្តភក្តិ ☐ ខ. ខ្ជិលរៀន និងនាំមិត្តភក្តិលេង

☐ គ. មិនស្តាប់គ្រូពន្យល់ និងបង្កជម្លោះ ☐ ឃ. យកចិត្តទុកដាក់រៀនសូត្រ និងជួយមិត្តភក្តិ

៣. តើនៅផ្ទះ សុខាបានធ្វើអ្វីខ្លះ?

☐ ក. មិនស្តាប់បង្គាប់ឪពុកម្តាយ ☐ ខ. ខិតខំរៀនបន្ថែម និងជួយធ្វើកិច្ចការងារផ្ទះ

☐ គ. មើលទូរស័ព្ទ និងទូរទស្សន៍ ☐ ឃ. ដើរលេង និងរំខានឪពុកម្តាយ

៤. ហេតុអ្វីបានចាឪពុកម្តាយសុខាសប្បាយចិត្ត ?

☐ ក. សុខាជាក្មេងឆ្លាត ☐ ខ. ឃើញកូនខិតខំរៀនសូត្រ និងរៀនពូកែ

☐ គ. រកការងារបានធ្វើ ☐ ឃ. រកលុយបានច្រើន

៥. ចូលគូសភ្ជាប់ពីសំណេរពាក្យ ទៅនឹងសំណួរពាក្យ ។

| សំណេរពាក្យ | សំណួរពាក្យ |
|---|---|
| ក. មិត្តភក្តិ | ១. [ ឡាត់-ធៈ-ផល់ ] |
| ខ. ឧស្សាហ៍ | ២. [ បត់-បញ់-ជា ] |
| គ. បទបញ្ជា | ៣. [ មិត-ភាក់ ] |
| ឃ. លទ្ធផល | ៤. [ អ៊ុស-សា ] |

LIVEWORKSHEETS

# សំណេរ

១. ចូរពន្យល់ពាក្យ " ឧស្សាហ៍  មិត្តភក្តិ  បទបញ្ញា " ។

- ឧស្សាហ៍ ..........................................................................................................។
- មិត្តភក្តិ ..........................................................................................................។
- បទបញ្ញា ..........................................................................................................។

២. ចូររកពាក្យបដិសព្ទនឹងពាក្យ " ហ៊ាន " ។

....................................................................................................................................។

៣. ចូររកពាក្យវេវចនសព្ទនឹងពាក្យ " ឪពុក " ។

....................................................................................................................................។

៤. ចូរជ្រើសរើសពាក្យក្នុងប្រអប់ ទៅបំពេញល្បះតាមរូបភាពខាងក្រោមឱ្យបានត្រឹមត្រូវ ។

| ការងារ | បង្រៀន | អាន |
|---|---|---|



ក. សុខា................សៀវភៅនៅផ្ទះ ។



ខ. សុខាជួយធ្វើ.................ផ្ទះ ។



គ. សុខាជួយ.................មិត្តភក្តិរួមថ្នាក់ ។

LIVEWORKSHEETS